**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ : ៨១២៧..សជណ.**

ថ្ងៃ ចន្ទ ១៤ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ពីរាជរដ្ឋាភិបាល រៀបចំក្រុមការងារបច្ចេកទេសតាក់តែងគោលនយោបាយលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨។

**យោង ៖** - លិខិតលេខ៣៥១ អ.ជ.ប.ជ.អ. ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- លិខិតលេខ៥៥៨ ខន/០២២ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២២។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ដូចខាងក្រោម៖

ក. រៀបចំគោលនយោបាយជាតិលុបបំបាត់ជំងឺអេដស៍នៅឆ្នាំ២០២៥ និងចីរភាពនៃកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨។

ខ. រៀបចំសមាសភាពក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឋានៈស្មើរដ្ឋមន្ត្រី១រូប | | ជាប្រធាន |
| ២- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាអនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | ជាអនុប្រធាន |
| ៤- រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | ជាអនុប្រធាន |
| ៥- អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | ១រូប | ជាអនុប្រធានប្រចាំការ |
| ៦- អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | ជាលេខាធិការ |
| ៧- ឯកឧត្តម លោកជំទាវតំណាងក្រសួង ស្ថាប័នដែលជាសមាជិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មួយចំនួនតាមការចាំបាច់ | | ជាសមាជិក |
| ៨- តំណាងអង្គការ UNAIDS | ១រូប | ជាទីប្រឹក្សា |

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**មាសសាឯម ដានី**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ឯកសារ កាលប្បវត្តិ